# VBNK សន្និសីទ

# ការសន្ទនា សហគមន៍ :

## “ ស្តីពីការធ្វើឱ្យសង្គមមួយមានភាពខុសប្លែកគ្នាពីថ្ងៃនេះ និងថ្ងៃស្អែក”

### បុព្វកថា

សន្និសីទគំរប់ខួប១០ឆ្នាំរបស់អង្គការ VBNK កាលពីឆ្នាំ២០០៧ " ស្តីពីការសន្ទនារវាងមនុស្សជំនាន់ផ្សេងៗគ្នា " បានផ្តោតលើបញ្ហាសង្គមសំខាន់ៗ ដូចជា : ការអប់រំ សីលធម៌ អំពើហិង្សាក្នុងគ្រួសារ ថ្នាំញៀន និងភាពក្រីក្រ ដែលជាការព្រួយបារម្ភដ៏ចំបងនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ ។ សិក្ខាកាមបានសំណូមពរឱ្យមានសន្និសីទមួយ ដើម្បីតាមដានត្រួតពិនិត្យទៅលើបញ្ហាទាំងនោះឱ្យកាន់តែស៊ីជំរៅ និងរុករកមធ្យោបាយដើម្បីធ្វើការរួមគ្នាឱ្យកាន់តែប្រសើរឡើងនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ននេះ និងនៅពេលអនាគត ។

### និស្សយ

ដើម្បីផ្តល់ឱ្យសមាជិកសហគមន៍ អ្នកអនុវត្តការងារអភិវឌ្ឍន៍ រដ្ឋអំណាចមូលដ្ឋាន និងមន្ត្រីរដ្ឋាភិបាល ដែលមានតាមក្រុមអាយុ និងមានបទពិសោធន៍ការងារផ្សេងៗគ្នា បានមកជួបជុំដើម្បីរំលឹកឡើងវិញពីប្រវត្តិសាស្រ្ត និងសង្គមខ្មែរ ដោយលើកយកពីបញ្ហាសង្គមសំខាន់ៗ ក្នុងជំនាន់ ឬរបបប្រវត្តិសាស្រ្តនិមួយៗ ហើយរុករកមធ្យោបាយដែលម្នាក់ៗ អាចរួមចំណែកក្នុងការដោះស្រាយបញ្ហាទាំងនោះ និងធ្វើឱ្យសង្គមមានការប្រែប្រួលក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ។

### គោលបំណង

នៅចុងបញ្ចប់នៃសន្និសីទនេះ អ្នកចូលរួមទាំងអស់ នឹងបាន :

- មានឱកាសដើម្បីពិភាក្សា និងរំលឹកពីព្រឹត្តិការណ៍សំខាន់ៗក្នុងសង្គមកម្ពុជានៅក្នុងបទពិសោធន៍ជីវិតរបស់ពួកគេដែលធ្លាប់ឆ្លងកាត់ ( ពីអតីតកាលមកដល់បច្ចុប្បន្នកាល )
- ទស្សនៈវិស័យ ដែលពួកគេចង់ឃើញសង្គមកម្ពុជានៅពេលអនាគត (ដល់ឆ្នាំ ២០១៥)
- កំណត់សកម្មភាពអ្វីមួយ ដែលអាចរួមចំណែក ( ពីថ្ងៃនេះ ) ដើម្បីសំរេចបានទស្សនៈវិស័យ (ឬកំណត់សកម្មភាពណាមួយដែលម្នាក់ៗ អាចរួមចំណែកដើម្បីធ្វើអោយមានភាពខុសប្លែកគ្នាពីក្នុងសង្គមបច្ចុប្បន្ននេះដើម្បីឈានទៅសំរេចទស្សនៈវិសយ័ខាងមុខ ) ។

## វិធីសាស្ត្រ

- ការពិភាក្សា បែបតុកាហ្វេ
- ការគូររូបភាព
- ការពិភាក្សា ជាក្រុម
- កំណត់ត្រាប្រចាំថ្ងៃ

## គោលរឿងសំខាន់ៗ

- ការអប់រំ
- សីលធម៌
- អំពើហិង្សានៅក្នុងគ្រួសារ
- ថ្នាំញៀន
- ភាពក្រីក្រ
- ព្រមទាំងមានរឿងផ្សេងៗទៀត ដែលបានមកពីការពិភាក្សានោះ

# ព័ត៌មានបន្ថែម

## កាលបរិច្ឆេទ និងទីកន្លែង

សន្និសីទត្រូវបានរៀបចំឡើងរយៈពេល ៣ថ្ងៃ គឺពីថ្ងៃទី ២៤ ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០០៨ នៅភោជនីយដ្ឋាន ជំនោរស៊ីសែន ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័ ។សិក្ខាកាមមកពីក្រៅ ស្រុកសេរីសោភ័ណ នឹងត្រូវរំពឹងថាបានធ្វើដំណើរមកកាន់ទីរួមខេត្តនៅថ្ងៃទី ២៣ ខែមិថុនា ដើម្បីបានចូលរួមក្នុង សន្និសីទនៅថ្ងៃដំបូងដែល នឹងចាប់ផ្តើមនៅវេលាម៉ោង ៨ ព្រឹក ។

VBNK នឹងផ្តល់ជូនលើការចំណាយថ្លៃធ្វើដំណើរ ទីកន្លែងស្នាក់នៅ និងសោហ៊ុយប្រចាំថ្ងៃ ដល់សិក្ខាកាម ដែលមកពីក្រៅស្រុក សេរីសោភណ៍ ។

## អ្នកចូលរួម

- នឹងមានសិក្ខាកាម ចំនួន ១០០ នាក់ ដែលមានអាយុផ្សេងៗគ្នា ចាប់ពីអាយុ ១៥ឆ្នាំ ទៅដល់អាយុ ៧០ឆ្នាំ
- នឹងត្រូវរៀបចំសិក្ខាកាមជា ៣ ក្រុម ដែលមាន អាយុដូចខាងក្រោម :

  **ក្រុម ក** : សិក្ខាកាមវ័យក្មេង ដែលមានអាយុចាប់ពី ១៥-២៩ឆ្នាំ កើតនៅចន្លោះ ឆ្នាំ១៩៧៩ និង ១៩៩៣

  **ក្រុម ខ :** សិក្ខាកាមវ័យកណ្តាល ដែលមានអាយុចាប់ពី ៣០-៥៣ឆ្នាំ កើតនៅចន្លោះឆ្នាំ១៩៥៥ និង ១៩៧៨

  **ក្រុម គ :** សិក្ខាកាមវ័យចំណាស់ ដែលមានអាយុចាប់ពី ៥៤ ឡើងទៅ កើតមុន ឆ្នាំ១៩៥៤
- នឹងមានសមាជិកសមាគមន៍ អ្នកអនុវត្តការងារអភិវឌ្ឍន៍សង្គម រដ្ឋអំណាចមូលដ្ឋាន និងមន្ត្រីការងារ រដ្ឋាភិបាលជាច្រើន ។
- នឹងមានអ្នកចូលរួម មកពីខេត្តបន្ទាយមានជ័យ បាត់ដំបង ឧត្តរមានជ័យ សៀមរាប ប៉ៃលិន និងពោធិ៍សាត់ ។

## ភាសា

សន្និសីទនេះ នឹងប្រព្រឹត្តទៅជាភាសាខ្មែរ ។

## ព័ត៌មាន

សំរាប់ព័ត៌មានបន្ថែមទៀតសូមទំនាក់ទំនងទៅកាន់បុគ្គលិករដ្ឋបាលផ្នែកបណ្តុះបណ្តាលនៅអង្គការ VBNK តាមរយៈទូរស័ព្ទលេខ ០២៣ ៧២២ ១១៥ និងអ៊ីម៉ែល registration@vbnk.org